22130565

International Baccalaureate®
Baccalauréat International
Bachillerato Internacional

**KHMER A: LITERATURE – HIGHER LEVEL – PAPER 1**
**KHMER A : LITTÉRATURE – NIVEAU SUPÉRIEUR – ÉPREUVE 1**
**KHMER A: LITERATURA – NIVEL SUPERIOR – PRUEBA 1**

Wednesday 8 May 2013 (morning)
Mercredi 8 mai 2013 (matin)
Miércoles 8 de mayo de 2013 (mañana)

2 hours / 2 heures / 2 horas

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Write a literary commentary on one passage only.
- The maximum mark for this examination paper is *[20 marks]*.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez un commentaire littéraire sur un seul des passages.
- Le nombre maximum de points pour cette épreuve d'examen est *[20 points]*.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario literario sobre un solo pasaje.
- La puntuación máxima para esta prueba de examen es *[20 puntos]*.


© International Baccalaureate Organization 2013

https://xtremepape.rs/

*សូមអ្នកសរសេរអត្ថាធិប្បាយបែបអក្សរសិល្ប៍ទៅលើអត្ថបទ**មួយ** ក្នុងចំណោមអត្ថបទខាងក្រោមនេះ៖*

**1.**

យើងមកពិចារណាពីអ្នកម្ដាយខេមា គាត់ជាស្រីរងការឈឺចាប់ ព្រោះតែការផិតក្បត់របស់ស្វាមី លោកស្រីគួរឲ្យអាណិតមែន តែថាមិនគួរខ្វះការអត់ធ្មត់ មិនចេះរកវិធីសាស្ត្របង្ក្រាបលោកប្ដី។ លោកស្រីភ្លេចគិតថា គេបង្ក្រាបបុរសដោយភាពទន់ភ្លន់នៃស្នាមញញឹម តែហ្មត់ចត់របស់ស្ត្រីយ៉ាងមានអនុភាព។ នេះលោកស្រីយកក្ដៅទល់ក្ដៅ ហិង្សាទល់ហិង្សា ហើយបណ្ដោយជីវិតស្ថិតក្នុងភាពមិនគួរប្រព្រឹត្ត ប្រាសចាកសេចក្ដីថ្លៃថ្នូរ បែបជាពាក្យប្រមាថកាតទាន ជេរប្រទេច វាយដំតតបជាមួយលោកប្រុសដែលកំពុងពាល ដូច្នេះលោកស្រីក៏ពាលជាមួយលោកប្រុសដែរ។ មិនតែប៉ុណ្ណោះខឹងប្ដី លោកស្រីក៏ដើរចោលផ្ទះចោលកូន ទៅជាមួយមិត្តស្រីៗជាលោកស្រីលោកជំទាវដើម្បីពិគ្រោះប្ដូរយោបល់រកវិធីប្រយុទ្ធតតាំងស្វាមីតាមវិធីដូចដែលយើងឃើញមកហើយ។ គាត់មិនគិតដល់កូនៗដែលគ្មានការកក់ក្ដៅពីឪពុក ហើយ ម្ដាយក៏ជាម្ដាយគ្មានផ្ដល់ការកក់ក្ដៅដែរ។ នេះ ឬ «ឆ្នាំងណាគ្របហ្នឹង»?

ដោយសារតែហេតុយ៉ាងនេះ បងប្អូនខេមាទាំងបីនាក់បាត់អស់ក្ដីសង្ឃឹម គ្មានស្គាល់អ្វីជាភាពកក់ក្ដៅដែលត្រូវបានពីម្លប់ទ្រូងរបស់ឪពុកម្ដាយដែលឪពុកម្ដាយទាំងឡាយតែងតែផ្ដល់ឱ្យកូនៗក្នុងលោក។ បងប្អូនខេមារស់តាមតែវាសនារុញច្រាន ដូចទូកកណ្ដាលទន្លេ រេតាមខ្យល់បក់បោក បើជាខ្យល់ជំនោរ ទូកក៏រសាត់ដូចគេឯង បើជាខ្យល់កំណាច ទូកនឹងជួបរឿងភ័យខ្លាចដោយការលិចលង់មិនខានឡើយ ឬក៏ដូចកូនចាបតូចខ្ចីដែលទើបនឹងបើកនេត្រាឃើញពន្លឺព្រះអាទិត្យសោះ ហើយក៏ត្រូវគេបង្ខំឱ្យរស់ដោយខ្លួនឯង ឬ ដូចផ្កាំរីកកំពុងរងព្យុះបក់បោកយ៉ាងសាហាវ។

ដូចយ៉ាងខេមាពេលនេះ នាងធ្លាក់ទៅក្នុងការអូសទាញរបស់បាបមិត្ត បែបលំអងនិងមិត្តភក្តិដែលជាក្រុមសាហាវឈាមរាវងើលភ្លើតភ្លើនសប្បាយឥតដឹងអ្វីជាល្អ ជាស ជាអាក្រក់ ជាខ្មៅទេ។ ពួកគេជាក្រុមមមាចឈ្លក់វង្វេងពន្លឺភ្លើង។ ហេតុអ្វីក៏មានក្រុមមមាចទាំងនេះ? ទាំងនេះវាមកពីមូលហេតុអ្វីខ្លះ? ចម្លើយព្រោះបរិយាកាសសង្គមវាជ្រួតជ្រាបលឿនណាស់ក្នុងចរន្តហោះហើរនៃការត្រូវការសេរីភាពឥតពិចារណារបស់យុវវ័យ របស់កុម៉ារដែលជាវ័យផុយស្រួយ ងាយបំផុតក្នុងការឆក់ឆាប ស្រូបយក... ព្រោះថាកាសែតវីដេអូពាលាអាវ៉ាសែអាសអាភាស សៀវភៅបែបអប់រំផ្ដេសផ្ដាស បនប៉ារ ខារ៉ាអូខេ ឪស្ដូតែក ផ្ទះទឹក ស្រីលក់ក្រូចច្របាច់និងអ្វីៗច្រើនទៀត ហើយក៏មាន



https://xtremepape.rs/

ការរួមចំណែកទទួលខុសត្រូវរបស់សាលារៀនដែលធ្វូររលុងក្នុងការគ្រប់គ្រងអប់រំសិស្សតាមបែបផ្ដេកផ្ដួលលើប្រាក់បៀវត្សមិនគ្រប់ចាយដែរ។ តែនេះក៏មិនអាចបន្ទោសខាងគ្រូបង្រៀននិងសាលារៀនឡើយ ព្រោះថាបើគ្មានបាយហូបឱ្យបានឆ្អែត តើនរណាមានកម្លាំងទៅបំពេញការងារ? ដូចនេះលោកគ្រូ អ្នកគ្រូអាចនឹងប្រើពេលវេលា ឬ មធ្យោបាយផ្សេងៗ ទោះជាមធ្យោបាយប្រការបែបណា គឺដើម្បីក្រពះគាត់សិនហើយ។ រួចក៏មិនអាចទាត់ចោលនូវការភ្ជាត់ភ្ជាំងរបស់ឪពុកម្ដាយ ឬ អាណាព្យាបាលដែលខ្វះការទទួលខុសត្រូវ ខ្វះការយកចិត្តទុកដាក់ដល់កូនដោយសារតែឪពុកម្ដាយខ្លះរស់ក្នុងភាពតោកយ៉ាកក្រីក្រ ក្នុងកាលៈទេសៈដែលប្រទេសជាតិទទួលការឆ្លងកាត់នៃសង្គ្រាមអូសបន្លាយ វាជាបច្ច័យអាក្រក់ប៉ះពាល់ធ្ងន់ធ្ងរដល់ការភ្ជាត់ភ្ជាំងភ្លេចនូវការទទួលខុសត្រូវទៅលើកូនពីសំណាក់ឪពុកម្ដាយ។ ព្រោះតែពួកគាត់មមាញឹកក្នុងជីវភាពរស់នៅ ហើយសង្គ្រាមវានាំមកដល់សង្គមនូវភាពផ្សេងទៀត គឺភាពជិតដាមជោកជាំនៃអំពើពុករលួយ អំពើហិង្សាជាដើមដល់កោសិកាសង្គមដែលវាសុទ្ធសឹងតែជះឥទ្ធិពលមិនល្អទៅលើយុវវ័យនិងកុមារយើង។ ឃើញថាអ្វីៗក្បែរខ្លួនពួកគេមានអានុភាព មានឥទ្ធិពលជំរុញឱ្យគេមើលឃើញដុំភ្លើងពណ៌លឿងដោយវង្វេងវង្វាន់ថាជាដុំមាស ព្រោះវាមានពណ៌លឿងដូចគ្នា។

ប៉ាល់ វណ្ណារីរក្ស, *បើផ្កាមានទឹក* (២០០៨)



https://xtremepape.rs/

**2.**

# ម្ដាយនឹកលុះផុត

ខែមួយ... ខែពីរ... ពីរដណ្ដប់    ហួរបាត់ស្ងាត់ស្ងប់ដូចសប្បាយ
តែចិត្តរលឹកនឹកនៃម្ដាយ    ហួរមូលក្នុងកាយជានិស្ស័យ ។
ឆ្នាំមួយម្ដាយព្រួយព្រោះព្រាត់កូន    បាត់សូន្យនៅសល់តែអាល័យ
អាលោះកូនពេកដេកស្រមៃ    យប់ថ្ងៃយល់សប្តិឃើញជីវ៉ា ។
ម្ដាយព្រួយក្រែងឯងមិនបានសុខ    នៅស្រុកឋានឆ្ងាយគ្មានអ្នកណា
បីបមថ្នាក់ថ្នមដោយស្នេហា    ដូចម្ដាយរក្សាគ្រប់វេលា ។
ឆ្នាំពីរម្ដាយអរកកាត់ចិត្ត    ឱយវិលផ្ដេកផ្ដិតលើវិជ្ជា
ដែលកូនខំរែងក្នុងវេទនា    ឱយបានសួគ៌ានាលោកិយ ។
ម្ដាយជូតទឹកភ្នែកគ្រប់យប់ថ្ងៃ    ឱយតែអ្នកថ្លៃមានរស្មី
ចំនេះចេះចប់ធ្វើមន្ត្រី    គប្បីអោយម្ដាយជ្រកបុណ្យផង ។
ឆ្នាំបីចូលមកថ្ងៃនេះហើយ    ទ្រូងម្ដាយបានស្បើយពីបំនង
ព្រោះហាក់ឃើញកូនដូចសព្វដង    ទៅវត្តលេងឆ្លងបុណ្យចូលឆ្នាំ ។
ម្ដាយទុកចំណីឆ្ងាញ់អោយកូន    តែនួននាងផ្ញើយតាមបណ្ដាំ
តាមទឹកតាមខ្យល់តាមម្ដាយចាំ    តាមម្ដាយផ្ដែផ្ដាំតាមសីលទាន ។
តែម្ដាយសូមឆ្លងសមុទ្រមក    វេចយកចំណីតាមម្ដាយមាន
គឺធម៌ គឺពរតាមធនធាន    ជាយានអោយកូនឆ្លងលោកា ។
ឆ្នាំមួយ រសាត់បាត់សោះសូន្យ    ឆ្នាំពីរចងក្បួន ឋានកាមា
អណ្ដែតឆ្លងទៅតាមសង្ខារ    ឆ្នាំបីទៀតណាក៏ជិតផុត ។
តែទុក្ខទួញធំទំទ្រូងម្ដាយ    នៅសួតខ្វល់ខ្វាយជាសមុទ្រ
នៃក្ដី រំលឹកបណ្ដូលបុត្រ    ម្ដាយនឹកលុះផុតឆ្នាំសង្សារ ។

កេង វ៉ាន់សាក់, *ចិត្តក្រមុំ* (១៩៥៤)



https://xtremepape.rs/